Honoring Choices® MASSACHUSETTS
*Your Health Care. Your Choice!*

# ការថែទាំសុខភាពរបស់អ្នក។ ជម្រើសរបស់អ្នក!

## តើនរណាជាភ្នាក់ងារថែទាំសុខភាពរបស់អ្នក?



**ចូលអាយុ 18 ឆ្នាំ អ្នកអាចជ្រើសរើសមនុស្សទុកចិត្តធ្វើជាភ្នាក់ងារថែទាំសុខភាពរបស់អ្នកបាន។**

ប្រសិនបើអ្នកឈឺ ហើយមិនអាចធ្វើការសម្រេចចិត្តលើការថែទាំដោយខ្លួនឯងបាន សូម្បីតែសម្រាប់ពេលខ្លីខណៈដែលអ្នកកាន់តែគ្រាន់បើហើយក៏ដោយ ភ្នាក់ងារថែទាំសុខភាពរបស់អ្នកមាន**អំណាច**ក្នុងការនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នក ហើយធ្វើការសម្រេចចិត្តដើម្បីយកការថែទាំជូនអ្នកជា ការថែទាំដែលអ្នកចង់បាន។ អ្នកតែងតាំងភ្នាក់ងារថែទាំសុខភាពរបស់អ្នកនៅក្នុងឯកសារជនតំណាងផ្នែកថែទាំសុខភាព។

**សូមធ្វើវាឥឡូវនេះ ដូច្នេះឯកសារជនតំណាងផ្នែកថែទាំសុខភាពគឺមានស្រេចពេលអ្នកត្រូវការ!**



1. ជ្រើសរើសមនុស្សដែលអ្នកទុកចិត្ត ដូចជាសមាជិកគ្រួសារ មិត្តភ័ក្តិ ឬនរណាក៏ដោយដែលអ្នកចូលចិត្តឲ្យធ្វើជាភ្នាក់ងារថែទាំសុខភាពរបស់អ្នក។




2. បោះពុម្ពឯកសារជនតំណាងផ្នែកថែទាំសុខភាពឥតគិតថ្លៃ។ (ជា 15 ភាសា) សរសេរឈ្មោះនៃភ្នាក់ងារថែទាំសុខភាពរបស់អ្នក ហើយបំពេញទម្រង់បែបបទ។

   ធ្វើបណ្ណកាបូបលុយ "ខ្ញុំមានឯកសារជនតំណាងផ្នែកថែទាំសុខភាព" ផ្ទាល់របស់អ្នក!




3. ឲ្យច្បាប់ចម្លងនៃឯកសារជនតំណាងផ្នែកថែទាំសុខភាពរបស់អ្នកទៅវេជ្ជបណ្ឌិតរបស់អ្នក និងអ្នកផ្តល់សេវាថែទាំរបស់អ្នក។ ពួកគេអាចហៅទូរសព្ទទៅភ្នាក់ងារថែទាំសុខភាពរបស់អ្នកនៅក្នុងពេលមានអាសន្ន។

**ចុះយ៉ាងម៉េចវិញប្រសិនបើខ្ញុំមិនអាចជ្រើសរើសភ្នាក់ងារថែទាំសុខភាពបាន?** គ្មានភ្នាក់ងារឬ? មិនអីទេ។ អ្នកអាចសរសេរនូវអ្វីដែលអ្នកចង់បានសម្រាប់ការថែទាំនៅក្នុង**សេចក្តីបង្គាប់ផ្ទាល់ខ្លួន (មរតកសាសន៍ពេលនៅរស់)** ហើយចែករំលែកជាមួយវេជ្ជបណ្ឌិតរបស់អ្នក។

ការចាប់ផ្តើមរហ័ស

**ទទួលបានឯកសារជនតំណាងផ្នែកថែទាំសុខភាព និងប័ណ្ណកាបូបលុយ។ អ្នកអាចធ្វើវាបានខ្លួនឯង!**

ស្កេនកូដ QR ឬចូលទៅកាន់ www.honoringchoicesmass/quick-start.com

### អង្គភាពរបស់អ្នកអាចចូលរួមនឹង *យុទ្ធនាការជំហានសាមញ្ញ*បាន

សមាគមសុខភាព និងមន្ទីរពេទ្យរដ្ឋ Massachusetts និងអង្គភាពឆ្លងតំណសម្ព័ន្ធនាំមុខគេកំពុងជួយមនុស្សពេញវ័យឲ្យអនុវត្តជំហានសាមញ្ញដើម្បីជ្រើសរើសភ្នាក់ងារថែទាំសុខភាព និងបំពេញឯកសារជនតំណាងផ្នែកថែទាំសុខភាព។ មកចូលរួមជាមួយយើង!

https://www.patientcarelink.org/a-simple-step-a-call-for-long-term-healthcare-planning/